


# កំណើនប្រជាជន និងការកើនឡើងនូវតម្រូវការផ្សេងៗពីបណ្ដាប្រទេសតាមដងទន្លេ ព្រមទាំងការប្រែប្រួលអាកាសធាតុ កំពុងដាក់សម្ពាធលើធនធាន និងនិរន្តរភាពទន្លេ

វៃ ដាក់ | Publication date 07 December 2021 | 18:24 ICT

Shares




រដ្ឋមន្ត្រីធនធានទឹកលោកលឹម គានហោ ពេលចូលរួមប្រជុំតាមវីដេអូក្នុងវេទិកាកិច្ចសហប្រតិបត្តិការធនធានទឹក ឡានឆាង-មេគង្គ លើកទី ២ នាថ្ងៃទី ៧-៨ ធ្នូ។ រូបថត MWRM page

**ភ្នំពេញ:** កំណើនប្រជាជន ការកើនឡើងនូវតម្រូវការសន្តិសុខទឹក ស្បៀងអាហារ និងថាមពលពីបណ្ដាប្រទេសតាមដងទន្លេ និងការអភិវឌ្ឍយ៉ាងឆាប់រហ័សគួបផ្សំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កំពុងដាក់សម្ពាធមកលើធនធាន និងនិរន្តរភាពទន្លេ ដែលទាមទារឱ្យប្រទេសនៅតាមដងទន្លេទាំងអស់ពង្រឹងកិច្ចសហប្រតិបត្តិការ គ្រប់គ្រង និងការអភិវឌ្ឍ ប្រកបដោយចីរភាព។ នេះបើតាមរដ្ឋមន្ត្រីធនធានទឹក។

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម លោកលឹម គានហោ បានថ្លែងបែបនេះ កាលពីថ្ងៃទី ៧ ខែធ្នូ តាមប្រព័ន្ធវីដេអូហ្វូម ពេលចូលរួមក្នុងវេទិកាកិច្ចសហប្រតិបត្តិការធនធានទឹក ឡានឆាង-មេគង្គ លើកទី២ ក្រោមប្រធានបទ «ធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈម និងជំរុញការអភិវឌ្ឍរួម» ដែលប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ គឺនៅថ្ងៃទី ៧-៨ ខែធ្នូនេះ តបតាមការអញ្ជើញរបស់លោក Li Guoying រដ្ឋមន្ត្រីក្រសួងធនធានទឹកនៃសាធារណរដ្ឋប្រជាមានិតចិន។

លោកថ្លែងថា សារៈសំខាន់នៃទន្លេមេគង្គ-ឡានឆាង ដែលផ្ដល់នូវធនធានទឹក និងធនធានពាក់ព័ន្ធ សម្រាប់ជួយជំរុញដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមសម្រាប់បណ្ដាប្រទេសតាមដងទន្លេ ក៏ដូចជាទ្រទ្រង់ដល់ជីវភាពរស់នៅនិងសុខុមាលភាពនៃប្រជាជនក្នុងអាងទាំងមូល។

លោកសង្កត់ធ្ងន់ថា៖ «ដោយសារតែបញ្ហាប្រឈម រួមមាន កំណើនប្រជាជន ការកើនឡើងនូវតម្រូវការសម្រាប់សន្តិសុខទឹក ស្បៀងអាហារ និងថាមពល នៅក្នុងបណ្ដាប្រទេសតាមដងទន្លេ និងការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងអាង គួបផ្សំនឹងផលប៉ះពាល់ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុដែលកើតឡើងបាននិងកំពុងដាក់សម្ពាធមកលើធនធាន និងនិរន្តរភាពទន្លេ»។

លោកបន្តថា កត្តានេះ ជាទំនួលខុសត្រូវរួមរបស់ប្រទេសតាមដងទន្លេទាំងអស់ ដែលចាំបាច់ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និងត្រូវធ្វើការរួមគ្នា ឆ្ពោះទៅសម្រេចបាននូវលទ្ធផលប្រកបដោយនិរន្តរភាពនៅក្នុងបរិបទធានាបាននូវសន្តិសុខទឹក ដើម្បីគាំទ្រដល់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់មេគង្គ-ឡានឆាង។

លោកលឹម គានហោ បានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗដែលសម្រេចបានរហូតមកទល់ពេលនេះក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ ដោយបានរួមចំណែកជួយបណ្ដាប្រទេសតាមដងទន្លេក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងបានជួយនាំមកនូវវិបុលភាពក្នុងតំបន់ប្រកបដោយផលិតភាព និងលទ្ធផលជាក់ស្ដែង ក្នុងនោះក៏រួមទាំងកិច្ចសហប្រតិបត្តិការធនធានទឹកផងដែរ។

លោកបានបង្ហាញនូវការប្ដេជ្ញាចិត្ត និងការត្រៀមខ្លួនរបស់កម្ពុជា ដើម្បីបន្តធ្វើការកាន់តែជិតស្និទ្ធក្នុងស្មារតីនៃការទទួលខុសត្រូវរួមគ្នាឆ្ពោះទៅការសម្រេចបាននូវវិបុលភាពរួមគ្នា ជាមួយនឹងកំណើនប្រកបដោយបរិយាប័ន្ន និងអនាគតប្រកបដោយចីរភាពសម្រាប់ប្រទេសតាមដងទន្លេនីមួយៗ និងសម្រាប់តំបន់ឡានឆាង-មេគង្គទាំងមូលរួមគ្នា។

តាមរយៈកិច្ចសហប្រតិបត្តិការធនធានទឹក ឡានឆាង-មេគង្គនេះ កាលពីថ្ងៃទី ២៥-២៦ ខែវិច្ឆិកា ឆ្នាំ ២០២១ មន្ត្រីរបស់កម្ពុជា ២រូប នៃក្រសួងបរិស្ថាន និងក្រសួងរ៉ែ និងថាមពល ក៏បានចូលរួមកម្មវិធីប្រកួតប្រជែងចិន អាស៊ាន ស្ដីពី សុវត្ថិភាព ទំនប់ទឹក (China-ASEAN Science Popularization Contest Focuses on Dam Safety) តាមប្រព័ន្ធវីដេអូហ្វូមផងដែរ។

កម្មវិធីប្រកួតប្រជែងស្ដីពីសុវត្ថិភាពទំនប់ទឹកនេះ លោក ប៊ុន វិចិត្រ មន្ត្រី នៃក្រសួងរ៉ែ និងថាមពល បានធ្វើបទបង្ហាញអំពី ទំនប់ វារីអគ្គិសនី សេសាន ក្រោម២ និងលោកហួ ថានិត មន្ត្រីនៃក្រសួងបរិស្ថាន បានធ្វើបទបង្ហាញ អំពីអត្ថប្រយោជន៍នៃអាងត្រពាំងថ្មស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យក្នុងការការពារបរិស្ថាន សេដ្ឋកិច្ចនិងសង្គម។

លោកហួ ថានិត ថ្លែងថា៖ «តាមរយៈកម្មវិធីនេះបានកសាងទំនាក់ទំនង និងសមត្ថភាពយុវជនយើងលើការសិក្សា ពីការគ្រប់គ្រង និងការរក្សាទឹកប្រកបដោយសុវត្ថិភាពខ្ពស់រវាងសាធារណរដ្ឋប្រជាមានិតចិន និងប្រទេសសមាជិកអាស៊ាន»៕

Contact author: វៃ ដាក់









## ព័ត៌មានថ្មីៗ

ក្រសួងរកឃើញអ្នកឆ្លងកូវីដចំនួន ៧ នាក់ថ្មីទៀត ខណៈអ្នកស្លាប់មាន ៣ នាក់និងអ្នកជាមានជាង១០នាក់

ហេតុផល Elon Musk ជាប់ជាបុគ្គលប្រចាំឆ្នាំរបស់ទស្សនាវដ្ដី Time

វត្តមានសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ បង្ហាញសញ្ញាវិជ្ជមាននៃការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា

ភាពតានតឹងភូមិសាស្ត្រនយោបាយ បង្កើនហានិភ័យនៃការកើនឡើងតម្លៃប្រេងឆៅ

លោកនាយករដ្ឋមន្ត្រីអំពាវនាវឱ្យម្ចាស់រថយន្តទាំងអស់ត្រូវរួសរាន់ទៅបង់ពន្ធ

កម្ពុជាពិចារណាពីការបង្កើនសិទ្ធិសម្រេចទៅអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត

ស្នេហ៍អូស្ត្រាលីគ្រោងជួលយន្តហោះឯកជន នាំយកផ្លែសំណព្វពីនូវែលសេឡង់ មកផ្ទះឱ្យទាន់គ្រិស្ដម៉ាស់

ស្ថាប័ន ៣ រួមគ្នាជំរុញគំរូអាជីវកម្មគិតពី ESG សម្រាប់និរន្តរភាព SME

ពលរដ្ឋ ១២ គ្រួសារព្រមរើចេញពីអគារជំនាន់បារាំងដែលចាស់ទ្រុឌទ្រោម

ស.ស.យ.ក. និងមន្ទីរអប់រំ សម្របសម្រួលផ្ដល់កន្លែងស្នាក់នៅនិងតម្រូវការខ្លះដល់សិស្សប្រឡងបាក់ឌុប



## អត្ថបទគួរចាប់អារម្មណ៍



ការប្រកួតកីឡាទោចក្រយាន ត្រូវពន្យារពេល ដើម្បីធ្វើឱ្យចំគោលដៅ



លោក ហ៊ុន សែន គ្រោងសរសេរសៀវភៅមួយក្បាលដែលនិយាយអំពីជីវិតជានាយករដ្ឋមន្ត្រី